**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការ និង សាសនា**

លេខ ១៧៧/២៣ ក.ធ.ស សរសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០១២ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងឥស្សរជន ជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ច របស់រដ្ឋលេខាធិការប្រចាំការ
- យោងតាមការចាំបាច់របស់ក្រសួងធម្មការ និងសាសនា។

## សម្រេច

**ប្រការ១ ..**

ត្រូវបានកំណត់ និងប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងធម្មការ និងសាសនា ដូចតទៅ៖

១. រដ្ឋមន្ត្រី ជាប្រធានស្ថាប័ន ទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររួមរបស់ក្រសួង និងទទួលបន្ទុកផ្ទាល់លើការងារអង្គភាពលទ្ធកម្ម អធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

២. ឯកឧត្តម **សេង សុមុនី** រដ្ឋលេខាធិការប្រចាំការ មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងជួយការងាររដ្ឋមន្ត្រី លើការងារប្រចាំថ្ងៃរបស់ក្រសួង ធ្វើបច្ចុប្បន្នភាព និងតាមដានវឌ្ឍនភាពការងារ លើកសំណើការងារអាទិភាពប្រចាំខែរបស់ថ្នាក់ដឹកនាំជូនរដ្ឋមន្ត្រី ស្របតាមគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ



ស្ទួនផ្សារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៥៥ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៥៥ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

- ពិនិត្យ និងសម្រេចអនុញ្ញាតច្បាប់ឈប់សម្រាករយៈពេលខ្លីចាប់ពី១ ថ្ងៃ ដល់៥ ថ្ងៃ ជូនមន្ត្រីរាជការក្រសួង ឋានៈក្រោមអគ្គនាយក និងអគ្គាធិការ
- ទទួលបន្ទុកការងារ នាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ដោក កុសល** អនុរដ្ឋលេខាធិការ ជាសេនាធិការ

៣. ឯកឧត្តម **ឆ្លោក ផន** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រី លើការងារនៅឧទ្ទកាល័យ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៤. ឯកឧត្តម **ញាណ តឿន** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រី លើការងារនៅឧទ្ទកាល័យ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៥. ឯកឧត្តម **នរៈ រតនចន្ទ្រនោ** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រី លើការងារនៅឧទ្ទកាល័យ
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តកំពង់ស្ពឺ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **សឿន សាន្ត** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

៦. លោកជំទាវ **ឱុច សារ៉ុម** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ផ្នែករដ្ឋបាល និងគណនេយ្យ (ការិយាល័យផែនការ និងគណនេយ្យ និងការិយាល័យគ្រប់គ្រងសម្ភារបរិក្ខារ) នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- ទទួលការងារសមាគមមន្ត្រីរាជការក្រសួង
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម រាជធានីភ្នំពេញ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ស្រេខ ខ៊ុចឡេខ** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

៧. ឯកឧត្តម **ញ៉ែម ម៉ាលី** រដ្ឋលេខាធិការ
- ឯកឧត្តម **ថោ តឿន** រដ្ឋលេខាធិការ
- ឯកឧត្តម **សន ម៉ីនហួរ** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖
- ទទួលបន្ទុកការងារពុទ្ធសាសនបណ្ឌិត្យ នៃអគ្គនាយកដ្ឋានកិច្ចការសាសនា
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តកែប
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **សឿន សាន្ត** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

៨. ឯកឧត្តម **ហាក់ ម៉ិនឡឿន** រដ្ឋលេខាធិការ
- ឯកឧត្តម **ម៉ែន មិថុល** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារ នាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយពុទ្ធសាសនាផ្សារភ្ជាប់សង្គម នៃអគ្គនាយកដ្ឋានកិច្ចការសាសនា
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តកណ្តាល និងខេត្តរតនគិរី។
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **សាន សម្ផស្ស** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

៩. ឯកឧត្តម **សារ៉ាយ ធុន** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ទទួលបន្ទុកការងារ នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តប៉ៃលិន
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ស្រេង ម៉ុងឡេង** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១០. ឯកឧត្តម **មាស សំណាង** រដ្ឋលេខាធិការ
- ឯកឧត្តម **កែ សំអឿន** រដ្ឋលេខាធិការ
- ឯកឧត្តម **ខួន ស្តេចតក្កី** រដ្ឋលេខាធិការ
- ឯកឧត្តម **នាក់ សំបូរ** រដ្ឋលេខាធិការ
- លោកជំទាវ **នួន ម៉ីនណា** រដ្ឋលេខាធិការ
- ឯកឧត្តម **ខិញ ហាឡៃហួន** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖
- ទទួលសម្របសម្រួលអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តព្រៃវែង កោះកុង ត្បូងឃ្មុំ កំពត កំពង់ធំ និងខេត្តបាត់ដំបង។
- ឯកឧត្តម **ចាន់ សេងចុង** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១១. ឯកឧត្តម **សាយ អំណាន** រដ្ឋលេខាធិការ
- លោកជំទាវ **មិន ចណ្ឌីរំលោភ** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖
- ទទួលបន្ទុកការងារ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តកំពង់ចាម
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។
- ឯកឧត្តម **ម៉ឺន បុណ្យសារ៉ាត់** អនុរដ្ឋលេខាធិការ ជាសេនាធិការ
- ឯកឧត្តម **ឡា ចិសេស** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១២. ឯកឧត្តម **សោម រតនា** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ទទួលបន្ទុកការងារ លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តព្រះសីហនុ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១៣. ឯកឧត្តម **ហាឡ្យ ចាន់ត្រីដា** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារ នាយកដ្ឋានទទួលពាក្យបណ្តឹង និងដោះស្រាយអធិករណ៍ នៃអគ្គនាយកដ្ឋានកិច្ចការសាសនា
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តស្វាយរៀង
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ផែន សុផាត** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១៤. ឯកឧត្តម **លន់ មុនីរតនា** រដ្ឋលេខាធិការ

- ឯកឧត្តម **ហ៊ឹម ចិបុលផល** រដ្ឋលេខាធិការ
- ឯកឧត្តម **ហ៊ឹម និមល** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារ នាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម ខេត្តឧត្តរមានជ័យ ព្រះវិហារ និងខេត្តក្រចេះ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ណុប ចន្ថារិទ្ធ** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១៥. ឯកឧត្តម **ឆាត សុឆេត** រដ្ឋលេខាធិការ

- ឯកឧត្តម **សៀ សុគ័ន្ធ្រា** រដ្ឋលេខាធិការ
- ឯកឧត្តម **យោប អះស្ការី** រដ្ឋលេខាធិការ
- ឯកឧត្តម **ឈិត សុគន្ធី** រដ្ឋលេខាធិការ
- ឯកឧត្តម **ឡា ឡៃ** រដ្ឋលេខាធិការ
- ឯកឧត្តម **ជា ណារ៉េត** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារ នាយកដ្ឋានពាហិរសាសនា នៃអគ្គនាយកដ្ឋានកិច្ចការសាសនា
- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម នៅខេត្តមណ្ឌលគិរី ខេត្តតាកែវ និងពាហិរសាសនាគ្រប់រាជធានី/ខេត្ត
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ខាន់ ខុន** អនុរដ្ឋលេខាធិការ ជាសេនាធិការ
- ឯកឧត្តម **ណូ ម៉ាត់សាត** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១៦. ឯកឧត្តម **អន ឆាខអាន** រដ្ឋលេខាធិការ

- ឯកឧត្តម **ផាន់ ចន្ទតារា** រដ្ឋលេខាធិការ
- ឯកឧត្តម **ហ៊ឹម ចិបុលឫទ្ធី** រដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារ នាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា នៃអគ្គនាយកដ្ឋានកិច្ចការសាសនា

- លើកកម្ពស់សាសនារបស់រដ្ឋ សុខដុមនីយកម្មសាសនា និងលើកកម្ពស់សីលធម៌សង្គម នៅខេត្តស៊ីងត្រែង សៀមរាប និងខេត្តបន្ទាយមានជ័យ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន
- ឯកឧត្តម **ផែន សុផាត** អនុរដ្ឋលេខាធិការ ជាសេនាធិការ
- ឯកឧត្តម **ម៉ិន បុណ្យសក្តិរ៉ាត់** អនុរដ្ឋលេខាធិការ ជាសេនាធិការ។

១៧. ឯកឧត្តម **តុប សារឿន** អនុរដ្ឋលេខាធិការ

មានភារកិច្ចដូចខាងក្រោម៖

- ទទួលការងារផ្សព្វផ្សាយព័ត៌មានក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ២ ..**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ..**

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ព្រះអគ្គាធិការ អធិការ ប្រធាននាយកដ្ឋាន ប្រធានផ្នែក ប្រធានមន្ទីរធម្មការ និងសាសនា រាជធានី-ខេត្ត ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួង និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៤រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០២៣

រដ្ឋមន្ត្រី

ចាយ_បុរិន

**កន្លែងទទួល៖**

-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ

-គណៈសង្ឃនាយកទាំងពីរគណៈ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ដូចប្រការ ៣

“ដើម្បីអនុវត្ត”

-ឯកសារ-កាលប្បវត្តិ